# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៦៤ សសរ

## សេចក្តីសំរេច
## ស្តីពី
## ការអនុញ្ញាតអោយមន្ត្រីរាជការលាឈប់ពីមុខតំណែង

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤០៤/០៥៩ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៤ ស្តីពីការផ្លាស់ប្តូរ តែងតាំង និងបែងចែកភារកិច្ចជូនឯកអគ្គរាជទូតប្រចាំនៅបរទេស
- បានឃើញសេចក្តីសំរេចលេខ ៣៩ សសរ ចុះថ្ងៃទី ១៦ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការបង្កើតគណៈកម្មការជាតិយូណេស្កូកម្ពុជា
- បានឃើញសេចក្តីសំរេចលេខ ៧៥ សសរ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ស្តីពីការបន្ថែមសមាសភាពនៃគណៈកម្មការជាតិយូណេស្កូកម្ពុជា
- យោងតាមសំណើរបស់ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា

## ស ំ រេ ច

**ប្រការ១ ..**

ត្រូវបានអនុញ្ញាតជូនលោកជំទាវ **ស៊ុន សារតឿន** លាឈប់ពីមុខតំណែង **អនុប្រធាន** នៃគណៈកម្មការជាតិយូណេស្កូកម្ពុជា ។

**ប្រការ២ ..**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មការជាតិយូណេស្កូកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង សាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២០ ខែតុលា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ២
- ឯកសារ-កាលប្បវត្តិ.